**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

# របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ ថ្លែងដោយឯកឧត្តមអុល វុី អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៃក្រសួងមុខងារសាធារណៈ ក្នុងឱកាសនៃពិធីសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅការងារបន្តសម្រាប់ឆ្នាំ២០១៩ របស់ក្រសួងមុខងារសាធារណៈ

នៅភោជនីយដ្ឋានទន្លេបាសាក់២ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩

- *សូមគោរពឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាទីគោរពដ៏ខ្ពង់ខ្ពស់!*
- *សូមគោរពឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ជាគណៈអធិបតី!*
- *ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័ន!*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាព និង ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ជាទីរាប់អាន!*
- *សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូលជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំបាទមានសេចក្តីសោមនស្ស រីករាយជាអនេកប្បការ ដោយមានកិត្តិយសជាតំណាងឱ្យគ្រប់អង្គភាពក្រោមឱវាទក្រសួងមុខងារសាធារណៈ រាយការណ៍អំពីលទ្ធផលការងារឆ្នាំ២០១៨របស់ក្រសួងមុខងារសាធារណៈ។ ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមគោរពអនុញ្ញាតពីឯកឧត្តមកិត្តិបណ្ឌិត **ពេជ្រ ប៊ុនធិន** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងគណៈអធិបតី អាននូវរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៨ របស់ក្រសួងមុខងារសាធារណៈ ជូនអង្គពិធីទាំងមូលដូចតទៅ៖

## ១- __សកម្មភាពថ្នាក់ដឹកនាំ__

ថ្នាក់ដឹកនាំក្រសួងបានអញ្ជើញចូលរួមកិច្ចប្រជុំ ការងារសង្គម និងពិធីផ្សេងៗ រួមមាន (១)អង្គប្រជុំពេញអង្គ គណៈរដ្ឋមន្ត្រី (២)ចូលរួមនិងដឹកនាំអង្គប្រជុំអន្តរក្រសួង (៣)វេទិកាសាធារណៈទៅតាមមុខសញ្ញាកំណត់ (៤)សម្ពោធសមិទ្ធផលនានានៅវត្តកំពែង នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ (៥)ចូលរួមកម្មវិធីនានាតាមការអញ្ជើញរបស់ គណៈកម្មាធិការរៀបចំបុណ្យជាតិនិងអន្តរជាតិ ព្រមទាំងក្រសួង ស្ថាប័ននានា (៦)កិច្ចប្រជុំកំពូល World Government Summit នៅទីក្រុងឌូបៃ ប្រទេសអារ៉ាប់រួម និង (៧)កិច្ចប្រជុំ

លើកទី៦៤ នៃក្រុមប្រឹក្សាប្រតិបត្តិ និង សន្និសីទនៃអង្គការតំបន់ភាគខាងកើតសម្រាប់រដ្ឋបាលសាធារណៈ នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី។

**២- សកម្មភាពជំនាញ**

**២.១- អង្គភាពថ្នាក់ជាតិ**

**២.១.១- ការងាររដ្ឋបាល**

- ក្រសួងបានទទួលលិខិតចូលចំនួន**៨៧៨១លិខិត** និង លិខិតចេញចំនួន**៥៥៣១លិខិត** ក្នុងនោះលិខិតបញ្ជាបេសកកម្មនិងឧទ្ទេសនាមចំនួន**១៣៥២លិខិត**
- បានរៀបចំកិច្ចប្រជុំចំនួន**៣៣៩លើក** នៅផ្ទៃក្នុងក្រសួងចំនួន**២១៤លើក** និងអន្តរក្រសួងចំនួន**១១៨លើក** ដែលមានសមាជិកចំនួន**១៣៤៦៦**នាក់។

**២.១.២- ការងារគ្រប់គ្រងបុគ្គលិក**

**ក- ការគ្រប់គ្រងស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការ**

- នៅចុងឆ្នាំ២០១៨ ក្រសួងមានមន្ត្រីរាជការសរុបចំនួន**១០៩៦នាក់** មានចំនួនស្ត្រី**៣៦៥នាក់** ប្រហែល**៣៣%** និង មន្ត្រីជាប់កិច្ចសន្យាសរុបចំនួន**២៩៨នាក់**។
- ចំនួនមន្ត្រីរាជការកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនិងឋានៈស្មើ រួមមាន (១)រដ្ឋមន្ត្រីនិងឋានៈស្មើរដ្ឋមន្ត្រីចំនួន**០២នាក់** (២)រដ្ឋលេខាធិការនិងឋានៈស្មើរដ្ឋលេខាធិការចំនួន**១៤នាក់** ចំនួនស្ត្រី**០៣**នាក់ ប្រហែល**២១%** (៣)អនុរដ្ឋលេខាធិការចំនួន២៥នាក់ ចំនួនស្ត្រី**០៤នាក់** ប្រហែល**១៦%** (៤)ខុទ្ទកាល័យចំនួន**៧នាក់**/ស្ត្រី**០១នាក់** (៥)អគ្គនាយកចំនួន**០៣នាក់** (៦) អគ្គាធិការចំនួន**០១នាក់** (៧)អគ្គនាយករងចំនួន**១២នាក់/ស្ត្រី០៣នាក់** (៨)អគ្គាធិការរងចំនួន**៧នាក់** (៩)នាយករងសាលាភូមិន្ទរដ្ឋបាលចំនួន**០៤នាក់/ស្ត្រី១នាក់** (១០)ប្រធាននាយកដ្ឋានចំនួន**១៦នាក់/ស្ត្រី១នាក់** (៩) អធិការចំនួន**១៣នាក់/ស្ត្រី៤នាក់** (១២)ប្រធានអង្គភាពលទ្ធកម្មចំនួន**០១នាក់** (១៣)អនុប្រធាននាយកដ្ឋានចំនួន**៩៤នាក់/ស្ត្រី២៥នាក់** ស្មើនឹង**២៧%** (១៤)ប្រធានការិយាល័យចំនួន**៦៣នាក់/ស្ត្រី២៤នាក់** ស្មើនឹង៣៨%(១៥)អនុប្រធានការិយាល័យចំនួន**៩២នាក់/ស្ត្រី៣៨នាក់** ស្មើនឹង**៤១%** (១៦)ជំនួយការចំនួន**៩នាក់** (១៧)ប្រធានលេខាធិការដ្ឋានចំនួន**០១នាក់/ស្ត្រី០១នាក់** (១៨)អនុប្រធានលេខាធិការដ្ឋានចំនួន**០២នាក់/ស្ត្រី០១**នាក់ (១៩)អនុ.អង្គភាពលទ្ធកម្មចំនួន**១នាក់/ស្ត្រី១នាក់** ។

**ខ- ការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ** ក្នុងឆ្នាំ២០១៨នេះ ការប្រែប្រួលស្ថានភាពរដ្ឋបាលគ្រួសារ សរុបមានចំនួន **៦៤៨** ករណី ។

**២.១.៣- ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ**

បានបញ្ជូនមន្ត្រីរាជការចូលរួមវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន**៩៨៤នាក់** ក្នុងនោះមានចំនួនស្ត្រី**១៣៤នាក់** ស្មើនឹង**១៤%**និង ក្រៅប្រទេសចំនួន**៤៧នាក់** ក្នុងនោះមានចំនួនស្ត្រី**០៨នាក់** ស្មើនឹង**១៧%**។

**២.១.៤- ការងារហិរញ្ញវត្ថុ ផ្គត់ផ្គង់ និងលទ្ធកម្ម**

**២.១.៤.១- ការងារហិរញ្ញវត្ថុ និង ផ្គត់ផ្គង់**

- បានរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០១៨និងផែនការសកម្មភាពប្រចាំត្រីមាសនីមួយៗ
- បានរៀបចំ និងបូកសរុបផែនការយុទ្ធសាស្ត្រថវិកា២០១៩-២០២១ និងបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទាន់ពេលវេលា
- បានប្រមូលផ្តុំ បូកសរុប និងរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ២០១៨

- បានរៀបចំកម្មវិធីចំណូល-ចំណាយថវិកាប្រចាំឆ្នាំ និងប្រចាំត្រីមាសនីមួយៗ របស់ក្រសួង និងអង្គភាពថវិការដ្ឋបាលកណ្តាលទាំង៤
- បានប្រមូលផ្តុំ ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងគ្រប់គ្រងគ្រប់សក្ខីប័ត្រចំណូល-ចំណាយនៃការអនុវត្តថវិកាកម្មវិធីប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំត្រីមាសនីមួយៗ ឆ្នាំ២០១៨
- បានពិនិត្យ ប្រមូលផ្តុំតម្រូវការ និងលើកគម្រោងផ្គត់ផ្គង់សម្ភារៈការិយាល័យ សង្ហារឹម សម្ភារៈបច្ចេកទេស និងការជួសជុលថែទាំផ្សេងៗជូនអង្គភាពក្រោមឱវាទ
- បានត្រួតពិនិត្យ និងប្រមូលសក្ខីប័ត្រដើម្បីទូទាត់ និងបើកផ្តល់បេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យាដែលបានចុះបំពេញការងារ
- បានពិនិត្យ និងរៀបចំបើកផ្តល់ប្រាក់បៀវត្សប្រចាំខែជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យាបានទាន់ពេលវេលា
- បានបើកផ្តល់ប្រេងឥន្ធនៈប្រចាំខែ
- បានចូលរួមរៀបចំការតាំងពិព៌ណនៅវិមានអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ
- បានចូលរួមរៀបចំសន្និបាតបូកសរុបលទ្ធផលការងាររយៈពេល៥ឆ្នាំ និងលើកទិសដៅការងារបន្ត
- បានចូលរួមធ្វើការផ្ទៀងផ្ទាត់បញ្ជីសារពើភ័ណ្ឌតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ នៅគ្រប់មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- បានរៀបចំបញ្ជីសារពើភ័ណ្ឌតារាងកើនឡើង-ថយចុះទ្រព្យសម្បត្តិរដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ របស់ក្រសួងមុខងារសាធារណៈ
- បានរៀបចំសេចក្តីជូនដំណឹងដល់គ្រប់អង្គភាព ស្តីពីការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងបានស្នើសុំគោលការណ៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចរាល់
- បានចូលរួមធ្វើសិក្ខាសាលាពិគ្រោះយោបល់ដើម្បី កែលម្អលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធព័ត៌មានវិទ្យា និងសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ៧២ អនក្រ.បក ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា នៅខេត្តសៀមរាប។

**២.១.៤.២- <u>ការងារលទ្ធកម្ម</u>**

**ក. គម្រោងលទ្ធកម្មសរុបទីស្តីការក្រសួងមុខងារសាធារណៈមានចំនួន ១៩ គម្រោង**

កិច្ចលទ្ធកម្មទាំងនោះអនុវត្តបាន១០០% ដែលក្នុងនោះមានជាអាទិ៍៖

-**<u>លទ្ធកម្មទំនិញ</u>**មានចំនួន **១៥** គម្រោងគឺ ទិញកុំព្យូទ័រយួរដៃ**ចំនួន១៣៥០គ្រឿង** សម្រាប់គាំទ្រដល់ដំណើរការនៃការអនុវត្តកម្មវិធីប្រឡងប្រណាំង អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងវិស័យសុខាភិបាល។

-**<u>លទ្ធកម្មសំណង់</u>**មានចំនួន **០២** គម្រោង (ក្នុងនោះរួមមានការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលបានខូចខាតក្នុងទីស្តីការក្រសួង និងសាងសង់របងលើដីបំរុងទុកសម្រាប់សាងសង់វិទ្យាស្ថានមុខងារសាធារណៈខេត្តត្បូងឃ្មុំ) មានការពិនិត្យ និងប្រគល់ ទទួល ការងារសាងសង់អគារសិក្សាថ្មីបន្ថែមរបស់សាលាភូមិន្ទរដ្ឋបាលដំណាក់កាលទី២ (៥០%)។

-**<u>លទ្ធកម្មសេវាកម្ម</u>**មានចំនួន **០២** គម្រោង។

**ខ. គម្រោងលទ្ធកម្មសរុបរបស់អង្គភាពថវិកាសាលាភូមិន្ទរដ្ឋបាល និងមន្ទីរមុខងារសាធារណៈទាំង២៥ មានចំនួន ១០៩ គម្រោង**

កិច្ចលទ្ធកម្មទាំងនោះអនុវត្តបាន១០០% ដែលក្នុងនោះមានដូចជា៖

-**<u>លទ្ធកម្មទំនិញ</u>**មានចំនួន **៩០** គម្រោង (ក្នុងនោះរួមមានការទិញរថយន្តចំនួន០២គ្រឿងរបស់មន្ទីរមុខងារសាធារណៈខេត្តបន្ទាយមានជ័យ និងខេត្តព្រះវិហារ)

-**<u>លទ្ធកម្មសំណង់</u>**មានចំនួន **១៧** គម្រោង (ក្នុងនោះរួមមានការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលបានខូចខាតក្នុងសាលាភូមិន្ទរដ្ឋបាល និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មួយចំនួន)

-**<u>លទ្ធកម្មសេវាកម្ម</u>**មានចំនួន **០២** គម្រោង។

### ២.១.៥- <u>ការងារនីតិកម្ម</u>

- បានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និង សំណើសុំកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងអង្គភាពចំណុះឱ្យក្រសួង ស្ថាប័នថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ចំនួន**៣០លើក**
- បានរៀបចំលិខិតគោរពជូនប្រមុខរាជរដ្ឋាភិបាលចំនួន២ អនុក្រឹត្យចំនួន**១៤** សេចក្តីសម្រេចចំនួន**១** ប្រកាសអន្តរក្រសួងចំនួន**២** និងសារាចរចំនួន**១**
- បានប្រជុំពិភាក្សាលើសេចក្តីព្រាង (១)ព្រះរាជក្រឹត្យស្តីពីការរៀបចំសាលាភូមិន្ទរដ្ឋបាល (២)អនុក្រឹត្យស្តីពីការដំឡើងប្រាក់បំណាច់មុខងារនិងប្រាក់ឧបត្ថម្ភជូនមន្ត្រីរាជការ (៣)អនុក្រឹត្យស្តីពីការកែសម្រួលនិងដំឡើងបច្ច័យនិច្ចភត្តប្រចាំខែជូនគ្រូពុទ្ធិកសិក្សា និង មន្ត្រីបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- បានចូលរួមកិច្ចប្រជុំគ្រប់កម្រិតចំនួន**៥៣លើក** ដើម្បីពិភាក្សាលើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តនានា
- បានធ្វើបទបង្ហាញក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលតាមក្រសួង ស្ថាប័ន និងអង្គភាពនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិចំនួន**២៥លើក** និង កម្មវិធីផ្សេងៗចំនួន**៣៩លើក**
- បានរៀបចំលិខិតឆ្លើយតបទៅនឹងសំណើរបស់ក្រសួង ស្ថាប័ន បានចំនួន**៣៧លិខិត**។

### ២.១.៦- <u>ការងារគ្រប់គ្រងក្របខណ្ឌ</u>

- បានធ្វើសំណើជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីស្នើសុំបញ្ចូលក្របខណ្ឌ**៦១កន្លែង** ជូនក្រសួងធម្មការនិងសាសនា ចំនួន**០២កន្លែង** និង ក្រសួងអប់រំ យុវជន និងកីឡាចំនួន**៥៩កន្លែង**
- បានបញ្ចូលក្របខណ្ឌគ្រូចេញថ្មីចំនួន**៣៣៧១នាក់** និង ជាបុគ្គលិកចំនួន**៣១៨នាក់** ដែលបានបញ្ចប់ការបណ្តុះបណ្តាលចេញគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន នៃក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា
- បានឯកភាពចំពោះសំណើ (១)សុំបន្ថែមគ្រូបង្រៀនពីរថ្នាក់ពីរពេលចំនួន**២៥៦កន្លែង** និងគ្រូបង្រៀនជាប់កិច្ចសន្យាចំនួន**៥០៤កន្លែង** របស់ក្រសួងអប់រំ យុវជន និងកីឡា (២)សំណើសុំប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាបន្ថែមចំនួន**០៦នាក់** ជាជំនួយការថ្នាក់ដឹកនាំរបស់ក្រសួងពាណិជ្ជកម្មឆ្នាំ២០១៨ (៣)សំណើសុំពិនិត្យនិងសម្រេចលើកិច្ចការបន្ត និងកែសម្រួលសមាសភាព មន្ត្រីជាប់កិច្ចសន្យាចំនួន**១០នាក់** ដើម្បីបម្រើការងារនៅសាកលវិទ្យាល័យក្រចេះឆ្នាំ២០១៨ (៤)សំណើសុំផ្លាស់ប្តូរការប្រើប្រាស់គ្រូជាប់កិច្ចសន្យាចំនួន**០៣នាក់** ទៅជាគ្រូថ្នាក់ពីរវេននិងគ្រូពីរវេនថ្នាក់គួបរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ

- បានរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្ស និស្សិត និងមន្ត្រីរាជការស៊ីវិលឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងមុខងារសាធារណៈ ក្រសួងយុត្តិធម៌ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងពាណិជ្ជកម្ម សម្រាប់ឆ្នាំ២០១៨
- បានផ្តល់ទិដ្ឋាការលើសំណើសុំ (១)ជ្រើសរើសក្របខណ្ឌចំនួន**០៨កន្លែង** (២)ជ្រើសរើសបេក្ខជនជាប់បំរុង ចំនួន**០៧កន្លែង** (៣)ប្រើប្រាស់ កែសម្រួល និងនិយ័តមន្ត្រីជាប់កិច្ចសន្យាចំនួន**១៤៣កន្លែង** (៤)ប្រើប្រាស់ គ្រូបង្រៀនជាប់កិច្ចសន្យាចំនួន**៥០៤កន្លែង** និង (៥)ប្រើប្រាស់គ្រូបង្រៀនបន្ថែមថ្នាក់ពីរវេន ពីរគួប និងផ្លាស់ប្តូរចំនួន**២៦១កន្លែង**
- បានបដិសេធលើសំណើសុំ (១)បញ្ចូលក្របខណ្ឌពិសេសចំនួន**៤២កន្លែង** (២)ប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ចំនួន**២០កន្លែង** (៣)គោលការណ៍ប្រឡងប្រជែងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាដែលមានសញ្ញាបត្រដោយពុំគិតពីលក្ខខណ្ឌអាយុ និង (៤)គោលការណ៍ប្រឡងផ្ទៃក្នុងដោយពុំគិតលក្ខខណ្ឌអាយុដើម្បីប្តូរប្រភេទក្របខណ្ឌចំនួន**៧១៦នាក់**
- បានរៀបចំកិច្ចប្រជុំ (១)អន្តរក្រសួង ស្ថាប័ន ដើម្បីប្រជុំពិភាក្សាលើការរៀបចំផែនការជ្រើសរើសក្របខណ្ឌ មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីជាប់កិច្ចសន្យាផ្ទាំទំនប់ប្រព័ន្ធធារាសាស្ត្រ គ្រូបង្រៀនពុទ្ធិកជាប់កិច្ចសន្យា គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល គ្រូបង្រៀនគួបគ្រប់កម្រិត និងគ្រូបង្រៀនជាប់កិច្ចសន្យា អប់រំក្រៅប្រព័ន្ធសម្រាប់ផែនការក្របខណ្ឌឆ្នាំ២០១៩ និង (២) ពិភាក្សាលើសំណើសុំរំលឹកប្រាក់កម្រៃប្រចាំខែជូនគ្រូបង្រៀនពុទ្ធិកសិក្សាជាប់កិច្ចសន្យាចំនួន**៣០៥អង្គ/នាក់**
- បានចាត់បញ្ជូនមន្ត្រី**៤២នាក់** ដើម្បីចូលរួមក្នុងដំណើរការប្រឡងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិលចំនួន**១៣ក្រសួង ស្ថាប័ន**
- បានផ្តល់ទិដ្ឋាការលើសំណើសុំក្របខណ្ឌថ្មីរបស់ក្រសួង ស្ថាប័ន សរុបចំនួន**១២៧៦នាក់** សម្រាប់ថ្នាក់ជាតិសរុបបានចំនួន **៨៥២នាក់** និងថ្នាក់ក្រោមជាតិសរុបបានចំនួន **៤២៤នាក់**។
- បានផ្តល់ទិដ្ឋាការលើសំណើសុំមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួង ស្ថាប័ន សរុបចំនួន **៩៩៣ នាក់**។

### ២.១.៧- ការងារត្រួតពិនិត្យរដ្ឋបាលនិងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

- បានធ្វើសំណើសុំសេចក្តីសម្រេចពីសម្តេចនាយករដ្ឋមន្ត្រីចំនួន **២៦៣៥១នាក់** និងបានផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័ន សរុបចំនួន៣០៥០៤នាក់។ (យោងតារាងខាងក្រោម)

| លរ | បរិយាយ | សំណើសុំការសម្រេចពីសម្តេចនាយករដ្ឋមន្ត្រី | | ផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័ន | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១ | ផ្ទេរក្របខណ្ឌ | ៣៤ | ៦ | ៦០១ | ១០៥ |
| ២ | តែងតាំង | ២៧២ | ០ | ៣៣៦០ | ៣៣ |
| ៣ | តាំងស៊ប់ | ១៣៤៦៣ | ៦២៩៩ | ៣៧០៦ | ២៤៤៤ |
| ៤ | ចូលនិវត្តន៍តាមកាលកំណត់ | ៤១៣ | ៨៦ | ២៩៤៨ | ១១៨៨ |
| ៥ | ចូលនិវត្តន៍មុនកាលកំណត់ | ១១ | ៣ | ៧៨ | ២៩ |
| ៦ | លុបឈ្មោះ | ២ | ០ | ១ | ០ |
| ៧ | ដំឡើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ | ១២១៥៦ | ៣៣១១ | ១៩៥៨៩ | ៤៨១០ |
| ៨ | រៀបបៀវត្សមូលដ្ឋាន | ០ | ០ | ១៧ | ៤ |

| លរ | បរិយាយ | សំណើសុំការសម្រេចពីសម្តេចនាយករដ្ឋមន្ត្រី | | ផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័ន | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ៩ | រៀបប្រាក់បំណាច់មុខងារ | 0 | 0 | ២០៤ | ១១ |
| **សរុប** | | **២៦៣៥១** | **៩៧០៥** | **៣០៥០៤** | **១២៦២៤** |

- បានពិនិត្យ និង ផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល(ប្រាក់បៀវត្ស) នៃក្រសួង ស្ថាប័ន សរុបមានចំនួន**៣៧៧៦៦នាក់** ក្នុងនោះមានស្ត្រី **ចំនួន ៩៩០៥នាក់** ស្មើនឹង**២៦%** ។(យោងតារាងខាងក្រោម)

| លរ | បរិយាយ | សរុប (នាក់) | ស្ត្រី (នាក់) |
|---|---|---|---|
| ១ | ជ្រើសរើសថ្មី | ២០៤០ | ៧៤៥ |
| ២ | តាំងស៊ប់ | ១៨៤៩ | ៧៣៦ |
| ៣ | តែងតាំង | ៣៩១០ | ៩០៦ |
| ៤ | ផ្ទេរចូល | ១២៤៥ | ៣៥៨ |
| ៥ | ចូលបម្រើការងារជាថ្មី | ៣៨៨ | ១១០ |
| ៦ | ប្រាក់បំណាច់ថ្នាក់ដឹកនាំ | ២៧៧ | ៣០ |
| ៧ | លាភការទីប្រឹក្សា | ១៧២២ | ២៣១ |
| ៨ | លាភការជំនួយការ | ៦៥៤ | ១៣៩ |
| ៩ | កែសម្រួលប្រាក់បំណាច់មុខងារ | ២០២៤ | ៥៣០ |
| ១០ | ប្តូរប្រភេទក្របខណ្ឌ | ១៦ | ២ |
| ១១ | ដំឡើងថ្នាក់ ឋានន្តរស័ក្តិ | ១៩២៩៦ | ៤៩១៦ |
| ១២ | ទំនេរគ្មានបៀវត្ស | ២១៨ | ៧០ |
| ១៣ | លុបឈ្មោះ | ៦៥០ | ១២៩ |
| ១៤ | ផ្ទេរចេញ | ៦២២ | ១២២ |
| ១៥ | ប្រាក់ឧបត្ថមម្តងគត់ជូននិវត្តជន | ៤៤៧ | ១៦៧ |
| ១៦ | ចូលនិវត្តន៍ | ៤៥៤ | ១៥៥ |
| ១៧ | ស្ថិតក្រៅក្របខ័ណ្ឌដើម | ១៣ | ២ |
| ១៨ | ចំនួនកូន | ១៤៥៣ | ៦៩ |
| ១៩ | ចំនួនប្រពន្ធ | ៤៨៨ | ៤៨៨ |
| | **សរុប** | ៣៧៧៦៦ | ៩៩០៥ |

- បានពិនិត្យឃើញប្រាក់បៀវត្សដែលបានបើកលើសត្រូវបង្វែរចូលថវិការដ្ឋវិញចំនួន **២.០៨៥.៥៤៩.៦៣៣ រៀល (ពីរពាន់ប៉ែតសិបប្រាំលាន ប្រាំរយសែសិបប្រាំបួនពាន់ ប្រាំមួយរយសាមសិបបីរៀល)**
- បានពិនិត្យ និង ផ្តល់ទិដ្ឋាការលើសលាកបត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ន តាមរយៈការប្រឡង ការជ្រើសរើសពិសេស និងការផ្ទេរចូលសរុបមានចំនួន ក្របខណ្ឌ(ក)**២២១២នាក់**

(ខ)៥៤៦នាក់ (គ) **១១៥នាក់** ក្នុងនោះមានចំនួនស្ត្រី **១៣២៤នាក់** ស្មើនឹង **៤៦%**។(យោងតារាងខាងក្រោម)

| ល.រ | បរិយាយ | ក្របខណ្ឌ | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ក | ខ | គ | សរុប | ស្ត្រី | |
| ១ | ប្រឡង | ២០៧៧ | ៥៥៦ | ១១៤ | ២៧៤៧ | ១២៤៨ | |
| ២ | ជ្រើសរើសពិសេស | ១២៦ | ៧ | ១ | ១៣៤ | ៧៣ | |
| ៣ | ផ្ទេរចូល | ៩ | ១ | ០ | ១០ | ៣ | |
| **សរុបរួម** | | **២២១២** | **៥៦៤** | **១១៥** | **២៨៩១** | **១៣២៤** | |

២.១.៨- <u>ការងារគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានិងឯកសារមន្ត្រីរាជការស៊ីវិល</u>

- បានរកឃើញប្រាក់បៀវត្សមិនប្រក្រតីដែលត្រូវបង្វែរថវិកាចូលរដ្ឋវិញមានចំនួន **៤.៣៤៩.០៩៧.៦៨៩ រៀល (បួនពាន់បីរយសែសិបប្រាំបួនលាន កៅសិបប្រាំពីរពាន់ ប្រាំមួយរយប៉ែតសិបប្រាំបួនរៀល)**
- បានឆ្លើយតបនិងដោះស្រាយសំណួរតាមប្រព័ន្ធ Hot Line បានចំនួន៨៩២ករណី
- ថែទាំកុំព្យូទ័រមេ (Servers) និង កុំព្យូទ័រភ្ញៀវ (Clients) សម្រាប់ប្រើប្រាស់ក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការស៊ីវិលនិងតារាងទូទាត់បៀវត្ស
- បានបណ្តុះបណ្តាលការប្រើប្រាស់ប្រព័ន្ធបញ្ជូននិងទទួលតារាងបៀវត្ស ដល់មន្ត្រីជំនាញគ្រប់គ្រងតារាងទូទាត់ បៀវត្សនៃមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត សរុបចំនួន **៨៥នាក់**
- បានចុះយកព័ត៌មាននិងថតសកម្មភាពថ្នាក់ដឹកនាំក្រសួង និង បានផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដើម្បីផ្សព្វផ្សាយនៅលើគេហទំព័រនិងបណ្តាញសង្គមរបស់ក្រសួង
- បាន (១)បញ្ចូលទិន្នន័យមន្ត្រីរាជការក្នុងប្រព័ន្ធព័ត៌មានវិទ្យាចំនួន**២៣៩៣៦នាក់** (២)សលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលបានឡើងផ្ទើរចំនួន**៣៦២៤៤នាក់** (៣)បានធ្វើកំណែក្នុងប្រព័ន្ធទិន្នន័យចំនួន**៣៤២៣៨នាក់**
- បានបោះពុម្ពតារាងទូទាត់បៀវត្សបានចំនួនន**៣២**អង្គភាព និង**២៥**រាជធានី ខេត្ត
- បានធ្វើការកែតម្រូវការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការ នៅថ្នាក់កណ្តាលសរុបចំនួន**៣៦៦៨៤នាក់** នៅថ្នាក់រាជធានី ខេត្ត សរុបចំនួន**១៥១២៧៥នាក់** (យោងតារាងខាងក្រោម)

| ល.រ | បរិយាយ | ថ្នាក់កណ្តាល | ថ្នាក់រាជធានី-ខេត្ត |
|---|---|---|---|
| ១ | មន្ត្រីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ២៤៦ | ៣០៥ |
| ២ | មន្ត្រីចូលបម្រើការងារវិញក្រោយពីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៣៥២ | ៥៦០ |
| ៣ | មន្ត្រីក្របខណ្ឌថ្មីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា | ២០៧២ | ៤៩៥០ |
| ៤ | មន្ត្រីក្របខណ្ឌថ្មីបញ្ចូលប្រាក់បៀវត្ស | ២០៨១ | ៧៤៦៩ |
| ៥ | មន្ត្រីតាំងស៊ប់ | ១៩០១ | ៨២៧៧ |

| លរ | បរិយាយ | ថ្នាក់កណ្ដាល | ថ្នាក់រាជធានី-ខេត្ត |
|---|---|---|---|
| ៦ | មន្ត្រីប្ដូរក្របខណ្ឌ | ៣៦ | ២១១៦ |
| ៧ | មន្ត្រីតែងតាំង | ៥១៦៦ | ៤០៣៥ |
| ៨ | មន្ត្រីទីប្រឹក្សា និង ជំនួយការ | ៣៩៤ | ០ |
| ៩ | មន្ត្រីដល់អាយុចូលនិវត្តន៍ | ៧៥៩ | ២៦៧៣ |
| ១០ | មន្ត្រីលាឈប់ពីការងារ | ៤៥៤ | ៤៤៨ |
| ១១ | មន្ត្រីស្លាប់ | ៥២ | ១៤៨ |
| ១២ | មន្ត្រីឡើងថ្នាក់ប្រចាំឆ្នាំ | ១៩០៥៣ | ៧០៧៤៩ |
| ១៣ | មន្ត្រីឡើងឋានន្តរស័ក្តិ | ៦៣ | ៣៤៦ |
| ១៤ | មន្ត្រីផ្ទេរចេញ | ៥៧៥ | ២៥០៧ |
| ១៥ | មន្ត្រីផ្ទេរចូល | ១២៤៦ | ២០៥៣ |
| ១៦ | មន្ត្រីសុំប្រាក់បំណាច់មុខងារ | ២៤៦ | ១៤៨៧ |
| ១៧ | បញ្ចូលកូន | ១៥៤៤ | ៨៥៩៨ |
| ១៨ | បញ្ចូលប្រពន្ធ | ៤៤៤ | ១៧៩៨ |
| ១៩ | បញ្ចូលប្រាក់តំបន់ | ០ | ២០១៤៥ |
| ២០ | បញ្ចូលប្រាក់ពីរវេន គួប | ០ | ១២៥៦៦ |
| | **សរុប** | **៣៦៦៨៤** | **១៥១២៧៥** |

**២.១.៩- ការងារមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជានិងកិច្ចសហប្រតិបត្តិការអន្តរជាតិ**

- បានសម្របសម្រួលរៀបចំឯកសារ (១)សម្រាប់ធ្វើលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីរាជការចំនួន **១០នាក់/ស្ត្រី ២នាក់** និង (២)ពន្យាសុពលភាពលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីរាជការចំនួន**០៤នាក់**
- បានសម្របសម្រួលបញ្ជូនមន្ត្រីចំនួន**០២នាក់** ដើម្បីចូលរួមដំណើរទស្សនកិច្ចសិក្សាស្តីពី "រដ្ឋបាលសាធារណៈ និងការគ្រប់គ្រងធនធានមនុស្ស" ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី**០១** ដល់ថ្ងៃទី**០៧ ខែមេសា ឆ្នាំ២០១៨** នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េ
- បានធ្វើការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹង ASEAN General និង កិច្ចសហប្រតិបត្តិការអាស៊ានស្តីពីកិច្ចការមុខងារសាធារណៈ ASEAN Cooperation on Civil Service Matters (ACCSM) ដើម្បីលើកកម្ពស់ការយល់ដឹងដល់មន្ត្រីរាជការទាំងអស់
- បានរៀបចំសម្របសម្រួល និង ធ្វើការកែសម្រួល សៀវភៅ ASEAN Coffee Table Book ដែលបានស្នើសុំ ដោយគណៈកម្មាធិការមុខងារសាធារណៈ (Civil Service Commission) នៃប្រទេសហ្វីលីពីន
- បានធ្វើការសិក្សាស្រាវជ្រាវអំពីវិទ្យាស្ថានមុខងារសាធារណៈរបស់បណ្ដាប្រទេសអាស៊ាន
- បានរៀបចំសម្របសម្រួលបញ្ជូនមន្ត្រីចំនួន**០២នាក់** ដើម្បីចូលរួមបេសកកម្មសិក្សាពហុប្រទេសស្តីពី "Multi-Counntry Observational Study Mission on Regulatory Review Enhancing Public Sector Productivity" ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី**១៩-២៣ ខែវិច្ឆិកា ឆ្នាំ២០១៨** នៅប្រទេសហ្វីលីពីន
- បានផ្សព្វផ្សាយវគ្គបណ្ដុះបណ្ដាលនៅប្រទេសឥណ្ឌាសម្រាប់ឆ្នាំ២០១៨-២០១៩។

២.១.១០- <u>ការងារអគ្គាធិការដ្ឋាន</u>

- បានចុះធ្វើការត្រួតពិនិត្យគ្រូបង្រៀនខ្មែរឥស្លាមក្របខណ្ឌនិងជាប់កិច្ចសន្យាបានចំនួន**២៤**រាជធានី-ខេត្ត
- បានចុះធ្វើការត្រួតពិនិត្យគ្រូពេទ្យក្របខណ្ឌពិសេសឆ្នាំ២០១៦ បានចំនួន២៥ខេត្ត និង អង្គភាពនានា ចំណុះ ក្រសួងសុខាភិបាល
- បានចុះធ្វើការត្រួតពិនិត្យមន្ត្រីសុខាភិបាលដែលមានមុខតំណែងអចិន្ត្រៃយ៍លើសពីមួយ នៅមន្ទីរសុខាភិបាលខេត្តតាកែវ កំពត បន្ទាយមានជ័យ ព្រៃវែង កំពង់ឆ្នាំង ត្បូងឃ្មុំ ក្រចេះ កំពង់ធំ បាត់ដំបង កោះកុង មណ្ឌលគិរី កណ្ដាល និងរាជធានីភ្នំពេញ
- បានចុះស្រាវជ្រាវករណីសុំកែតម្រូវឆ្នាំកំណើតរបស់មន្ត្រីនៃមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង
- បានចុះស្រាវជ្រាវ និង ប្រមូលឯកសារពាក់ព័ន្ធនឹងការបញ្ចប់មុខតំណែងប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិបាលស្រុកលាប្អៀរ នៃមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ឆ្នាំង
- បានចុះត្រួតពិនិត្យគ្រូពុទ្ធិកជាប់កិច្ចសន្យាចំនួន**១៦០អង្គ/នាក់** ដែលបង្រៀននៅតាមពុទ្ធិកសិក្សានៃក្រុង/ស្រុក ទាំង**១០**ចំណុះឱ្យមន្ទីរធម្មការនិងសាសនាខេត្តកំពង់ចាម
- បានចូលរួមសិក្ខាសាលា ស្ដីពីការផ្សព្វផ្សាយរបាយការណ៍ស្ដីពីលទ្ធផលពិនិត្យតាមដានការគ្រប់គ្រងបុគ្គលិកអប់រំនិងវិធានការដោះស្រាយបញ្ហាប្រឈមនៅវិទ្យាស្ថានគរុកោសល្យខេត្តកំពង់ចាមនិងខេត្តបាត់ដំបង។

២.១.១១- <u>ការងារសវនកម្មផ្ទៃក្នុង</u>

- បានចុះប្រមូលព័ត៌មាននិងធ្វើសវនកម្មនៅមន្ទីរមុខងារសាធារណៈរាជធានី-ខេត្តចំនួន២៥អង្គភាព ព្រមទាំងបានផ្ដល់អនុសាសន៍កែលម្អប្រព័ន្ធគ្រប់គ្រងការងារ និងហិរញ្ញវត្ថុនៅមន្ទីរទាំងនោះ និងបានរៀបចំរបាយការណ៍សង្ខេបសវនកម្ម របាយការណ៍បញ្ចប់សវនកម្ម គោរពជូនឯកឧត្ដមកិត្តិបណ្ឌិតរដ្ឋមន្ត្រី អាជ្ញាធរសវនកម្មជាតិ អគ្គនាយកដ្ឋានសវនកម្មក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ទីរដើម្បីអនុវត្ត
- បានចុះតាមដានការអនុវត្តអនុសាសន៍សវនកម្មនៅមន្ទីរមុខងារសាធារណៈរាជធានី/ខេត្តចំនួន**២២**
- បានរៀបចំនិងដាក់ឱ្យអនុវត្តផែនការសវនកម្មឆ្នាំ២០១៩ កម្មវិធីសវនកម្មឆ្នាំ២០១៩ និង ប្រកាសលេខ២៩២៨មស.សវផ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅការិយាល័យសវនកម្ម បច្ចេកវិទ្យាព័ត៌មានចំណុះនាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមុខងារសាធារណៈ។

២.១.១២- <u>ការងារកែទម្រង់រដ្ឋបាលសាធារណៈ</u>

ក- <u>ការងារសេវាសាធារណៈ</u>

- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីសេវាសាធារណៈ ចំនួន **០៤លើក**
- បានរៀបចំបោះពុម្ពកម្រងឯកសារស្ដីពីការអនុវត្តអនុក្រឹត្យស្ដីពី ការវាយតម្លៃនិងការទទួលស្គាល់អង្គភាព ផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានដាក់ឱ្យអនុវត្តសេចក្ដីសម្រេច ស្ដីពីការដាក់ឱ្យអនុវត្តតារាងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល
- បានរៀបចំតារាងលក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ និង ការទទួលស្គាល់អង្គភាពផ្ដល់សេវាសាធារណៈគំរូក្នុងចំណោមវិទ្យាល័យដែលជាគ្រឹះស្ថានរបស់រដ្ឋទូទាំងប្រទេស មន្ទីរពេទ្យបង្អែកក្រុង

ស្រុក ខណ្ឌ ដែលផ្តល់ សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ (CPA1) កម្រិត២ (CPA2) និង កម្រិត៣ (CPA3)

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយការដាក់ឱ្យដំណើរការគេហទំព័រច្រកទ្វារអេឡិចត្រូនិក និង ផ្តល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway)
- បានពិនិត្យនិងកែសម្រួលកម្រងព័ត៌មានសេវាសាធារណៈរបស់ក្រសួង ស្ថាប័នចំនួន**០៧** និង ធ្វើបច្ចុប្បន្នភាព ចំនួន**០៨**ក្រសួង ស្ថាប័ន ដើម្បីដាក់ឱ្យដំណើរការតាមច្រកទ្វារអេឡិចត្រូនិកនិងផ្តល់ព័ត៌មានសេវាសាធារណៈ
- បានប្រជុំពិភាក្សាលើ (១)អនុវត្តគម្រោងការកែលម្អផ្តល់សេវាសាធារណៈ នៅក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (២)ការផ្ទេរការអនុវត្តមុខងារនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ ទៅថ្នាក់ក្រោមជាតិ (៣)ផលិតភាពនៃការប្រើប្រាស់ធនធានមនុស្សក្នុងវិស័យរដ្ឋបាលសាធារណៈ
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការកែលម្អគុណភាពសេវាសាធារណៈ" និង "ការប្រើប្រាស់ ការបញ្ចូលទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានសេវាសាធារណៈនៅក្នុងច្រកទ្វារអេឡិចត្រូនិក និងផ្តល់ព័ត៌មានសេវាសាធារណៈ" និង សិក្ខាសាលាស្តីពី "ការរៀបចំឯកសារណែនាំស្តីពីការផ្តល់សេវាសាធារណៈអាស៊ាន" និង "ការអនុវត្តសេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ" ព្រមទាំង "ការផ្លាស់ប្តូរបទពិសោធន៍ក្នុងក្របខណ្ឌ នៃការអនុវត្តគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការនិងរដ្ឋបាល"
- បានចុះជួបសម្ភាសន៍ជាមួយមន្ត្រីជំនាញនៃនាយកដ្ឋានមុខងារនិងធនធាន ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានជំរុញបង្កើតគណៈកម្មការវាយតម្លៃ និង ការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងសុខាភិបាល ថ្នាក់ខេត្ត ក្រុង និងស្រុក បានចំនួន**១៦**ខេត្ត និងរាជធានី។

**ខ- <u>ការងារត្រួតពិនិត្យនិងវាយតម្លៃ</u>**

- បានរៀបចំឯកសារស្តីពីបុព្វហេតុ សមិទ្ធផល បញ្ហាប្រឈម និងទស្សនៈវិស័យនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (NPAR)
- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ(គករ) ស្តីពីរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ(NPAR)ឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ និង រៀបចំរបាយការណ៍សង្ខេបជូនសម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានរៀបចំធ្វើបច្ចុប្បន្នភាពវឌ្ឍនភាពទិន្នន័យការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ (NPAR) ២០១៥, ២០១៦ និង ២០១៧ របស់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ**១២**ក្រសួង ស្ថាប័ន និង **៧**ខេត្ត
- បានរៀបចំរបាយការណ៍បូកសរុបលទ្ធផល ស្តីពីការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ NPAR របស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៥ នៃ រដ្ឋសភា ជូនក្រសួង ស្ថាប័នចំនួន**៣០** រាជធានី-ខេត្តចំនួន**២៥** និងសាកលវិទ្យាល័យនិងវិទ្យាស្ថានចំនួន**៣៨**
- បានធ្វើបច្ចុប្បន្នភាពតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ NPAR និង វិស័យមុខងារសាធារណៈ បានចំនួន**៨៨លិខិត**

- បានរៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីបង្គោលនៃក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈចំនួន០៤ខេត្ត ស្តីពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ NPAR និង សិក្ខាសាលាបូកសរុបលទ្ធផលនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ NPAR ២០១៥-២០១៨
- បានរៀបចំកម្មវិធីសិក្ខាសាលាពិគ្រោះយោបល់លើ ការរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ NPAR ២០១៩-២០២៩
- បានស្នើសុំបញ្ចូលសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈទៅក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- បានរៀបចំសូចនាករ កម្រងសំណួរ និងផែនការលំអិត ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយសេវាសាធារណៈ និងគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ នៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈខេត្តតាកែវ កំពត និង កំពង់ចាម
- បានចូលរួមជាវាគ្មិនក្នុងការចែករំលែកចំណេះដឹង និង បទពិសោធន៍ពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ លើប្រធានបទ "Dynamic Organization"
- បានសិក្សាឯកសារស្តីពី (១)"ក្របខណ្ឌនៃការវិនិច្ឆ័យនិងការវាយតម្លៃលើការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ" និង "ការវាយតម្លៃលើអភិបាលកិច្ចនិងការគ្រប់គ្រងហានិភ័យ" ដែលចេញផ្សាយដោយធនាគារអភិវឌ្ឍអាស៊ី និង(២)"លទ្ធកម្មលើភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន" ដែលចេញផ្សាយដោយធនាគារពិភពលោក។

គ- **<u>ការងារអភិវឌ្ឍន៍ធនធានមនុស្សនិងស្ថាប័ន</u>**

- បានបំពេញកម្រងសំណួររបស់អង្គការ OECD រួមមាន (១)យុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា (២)រដ្ឋាភិបាលបើកចំហនិងការបើកចំហទិន្នន័យ និង (៣)ការបង្កើតសូចនាករ ដើម្បីគាំទ្រដល់ការប្រើប្រាស់បច្ចេកទេសប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យមុខងារសាធារណៈ
- បានផ្តល់យោបល់ជូន (១)ក្រសួងបរិស្ថាន និង ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ លើការរៀបចំគោលនយោបាយធនធានមនុស្ស (២)ក្រសួងមុខងារសាធារណៈ និង ក្រសួងមហាផ្ទៃ លើការរៀបចំការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង និង/ឬ មុខតំណែងវិជ្ជាជីវៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង (៣)ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីគន្លងអាជីពគ្រូបង្រៀន
- បានចូលរួម (១)ពិនិត្យសេចក្តីព្រាងឯកសារស្តីពីការធ្វើបច្ចុប្បន្នភាព និង ពិនិត្យឡើងវិញការអនុវត្តផែនការសកម្មភាពគោលនយោបាយធនធានមនុស្សក្នុងវិស័យអប់រំ (២)ពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ និង (៣)សិក្ខាសាលាស្តីពី Formulating Concept of ARC: A-EXPECS 2018 នៅសាធារណៈរដ្ឋឥណ្ឌូនេស៊ី
- បានពិភាក្សាជាមួយ (១)JICA ពីការរៀបចំការងារគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈរយៈពេល១០ឆ្នាំ និង (២)GIZ លើករណី (ក)សេចក្តីព្រាងអនុក្រឹត្យស្តីពី "ការដាក់ឱ្យអនុវត្តការពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ" និង "ប្រព័ន្ធគ្រប់គ្រងគុណផល" (ខ)វគ្គបណ្តុះបណ្តាលស្តីពី "គ្រូបង្គោលដើម្បីផ្សព្វផ្សាយនិងជំរុញការ

អនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល" និង "ការគ្រប់គ្រងគម្រោងនិងវិធីសាស្ត្ររៀបចំគម្រោង" និង (គ) សិក្ខាសាលាស្តីពីរចនាសម្ព័ន្ធគំរូអង្គភាពធនធានមនុស្ស

- បានរៀបចំដាក់ឱ្យអនុវត្តសាកល្បងលើប្រព័ន្ធគ្រប់គ្រងគុណផល សម្រាប់ការិយាល័យច្រកចេញចូលតែមួយ ដែលមានតាមដំណាក់ រួមមាន (១)បានរៀបចំសិក្ខាសាលាប្រមូលធាតុចូលពីអង្គភាពនិងអ្នកពាក់ព័ន្ធ ដើម្បីត្រៀមដាក់ឱ្យអនុវត្តសាកល្បងច្រកចេញចូលតែមួយនៅខេត្តបាត់ដំបង និង ខេត្តកណ្តាល (២)បានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីជំនាញក្នុងស្រុកមោងឫស្សីនិងក្រុងបាត់ដំបង ដើម្បីត្រៀមដាក់ឱ្យអនុវត្តច្រកចេញចូលតែមួយ (៣)ដាក់ឱ្យអនុវត្តសាកល្បងលើប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់ការិយាល័យច្រកចេញចូលតែមួយនៅស្រុកមោងឫស្សី និង ក្រុងបាត់ដំបង (៤) បានចុះត្រួតពិនិត្យនិងជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់ការិយាល័យច្រកចេញចូលតែមួយ (៥)បានពិភាក្សាជាមួយតំណាងអង្គការ GIZ ស្តីពីសេចក្តីព្រាងឯកសារវគ្គបណ្តុះបណ្តាលប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់ ការិយាល័យច្រកចេញចូលតែមួយ (៦)បានចូលរួមរៀបចំកម្មវិធីបណ្តុះបណ្តាលលើកទី២ ស្តីពីប្រព័ន្ធគ្រប់គ្រងគុណផលនៅការិយាល័យច្រកចេញចូលតែមួយនៅក្នុងក្រុងបាត់ដំបងនិងស្រុកមោងឫស្សី នៃខេត្តបាត់ដំបង
- បានរៀបចំ (១)វគ្គបណ្តុះបណ្តាលស្តីពី "ការចែករំលែកចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ" ចំនួន០២លើក "គ្រូបង្គោល ដើម្បីផ្សព្វផ្សាយនិងជំរុញការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល នៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ" "ស្តីពីប្រព័ន្ធគ្រប់គ្រងគុណផលដល់មន្ត្រីបង្គោលនៃក្រសួងមុខងារសាធារណៈ" (២)សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពី "ប្រព័ន្ធគ្រប់គ្រងគុណផល" នៅខេត្តកំពត "ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល" ខេត្តមណ្ឌលគិរី និង "ការផ្សព្វផ្សាយរបាយការណ៍នៃការសិក្សាលើមុខងាររចនាសម្ព័ន្ធ និងនីតិវិធីបំពេញការងាររបស់អង្គភាពធនធានមនុស្សនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ"
- បានធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង ស្ថាប័នចំនួន១០
- បានរៀបចំឯកសារសម្រាប់សិក្ខាសាលាពិគ្រោះយោបល់និងប្រមូលធាតុចូល ដើម្បីរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ NPAR ឆ្នាំ២០១៩-២០២៨។

**ឃ- <u>ការងារគោលនយោបាយលាភការនិងសមិទ្ធកម្ម និង ក្រុមការងារកែទម្រង់បៀវត្ស</u>**

- ចុះសិក្សាលើការបើកប្រាក់បំណាច់ប្រចាំខែសម្រាប់ក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មន្ត្រីភូមិ និងប្រធានការិយាល័យប្រជាពលរដ្ឋរបស់ខេត្តសៀមរាប
- បានរៀបចំវិភាគទិន្នន័យការចុះត្រួតពិនិត្យការប្រើប្រាស់មន្ត្រីរាជការ និង មន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងសុខាភិបាលទូទាំងប្រទេស
- បានប្រមូលទិន្នន័យ និង រៀបចំសេចក្តីព្រាងឯកសារ ស្តីពីករណីសិក្សាការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ និង ចូលរួមប្រជុំស្តីពីវឌ្ឍនភាពនៃការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ
- បានដឹកនាំកិច្ចប្រជុំដើម្បីពិភាក្សាលើ (១)ការរៀបចំយុទ្ធសាស្ត្របៀវត្សឆ្នាំ២០១៩-២០២៣ (២) ការរៀបចំគោលនយោបាយដំឡើងប្រាក់បៀវត្សមូលដ្ឋានសម្រាប់ឆ្នាំ២០១៩ (៣)ការដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិលក្នុងឆ្នាំ២០១៩ (៤)ការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ (៥)ការរៀបចំបច្ច័យនិច្ចភត្តសម្រាប់មន្ត្រីសង្ឃ (៦)ការដំឡើងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការ (៧)ការដំឡើងប្រាក់បំណាច់មុខងារជូន

មន្ត្រីនគរបាលជាតិកម្ពុជា យោធិនកងយោធពលខេមរភូមិន្ទ និងមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ (៨) ការដំឡើងប្រាក់បំណាច់មុខងារជូនសមាជិកក្រុមប្រឹក្សា និងមន្ត្រីភូមិនៅថ្នាក់ក្រោមជាតិ (៩)នីតិវិធីនៃការបើកបៀវត្សរ៍២ដងក្នុង១ខែ (១០)ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះឱ្យនាយកដ្ឋានរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ (១១)ការរៀបចំនិងការប្រព្រឹត្តទៅរបស់អធិការដ្ឋានរដ្ឋបាលព្រៃឈើ និង ប្រកាសចំនួន០៥របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១២)ការគ្រប់គ្រងមន្ត្រីរាជការសុខាភិបាលតាមប្រព័ន្ធព័ត៌មានវិទ្យា, ការបង្កើតមន្ទីរពេទ្យបង្អែក០១ និង តម្លើងប៉ុស្តិ៍សុខភាព០៤ ទៅជាមណ្ឌលសុខភាពនៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ និង សំណើចំនួន១១ របស់ក្រសួងសុខាភិបាល (១៣)ការបង្កើតវិទ្យាស្ថានជាតិការងារ ការដំឡើងកម្រិតបណ្តុះបណ្តាលនិងប្រែក្លាយឈ្មោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ លើរចនាសម្ព័ន្ធ ការប្តូរឈ្មោះ និងដំឡើងឋានៈវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា ទៅជាវិទ្យាស្ថានជាតិសហគ្រិនភាពនិងនវានុវត្តន៍មានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាន និង ការរៀបចំនិងប្រព្រឹត្តទៅរបស់វិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជាប្រចាំនៅបរទេស របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (១៤)ការបង្កើតការិយាល័យចំនួន៤ និង ដេប៉ាតឺម៉ង់ចំនួន៥ ក្នុងរចនាសម្ព័ន្ធរបស់វិទ្យាស្ថានជាតិអប់រំពិសេស ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ ការបង្កើតនិងការកែសម្រួលរចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យ និង វិទ្យាស្ថានគរុកោសល្យ ការបង្កើតការិយាល័យចំនួន៥ក្នុងរចនាសម្ព័ន្ធរបស់នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធ និង សំណើចំនួន០៧ របស់ក្រសួងអប់រំ យុវជន និងកីឡា (១៥)ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល (១៦)ការរៀបចំដំណើរការខុទ្ទកាល័យ (១៧)សំណើចំនួន០២ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (១៨)ការបង្កើតការិយាល័យប្រែប្រួលអាកាសធាតុនៃនាយកដ្ឋានផ្លូវលំជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ (១៩)ការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងសុខាភិបាល (២០)ការបង្កើតអង្គភាពស្រាវជ្រាវអំពីប្រជាជននិងគោលនយោបាយអភិវឌ្ឍន៍ចំណុះឱ្យអគ្គលេខាធិការដ្ឋានប្រជាជន និង ការអភិវឌ្ឍ របស់ក្រសួងផែនការ និង (២១)សារាចរណែនាំរួមរវាងក្រសួងមុខងារសាធារណៈ និង ក្រសួងសុខាភិបាល ស្តីពីការធ្វើបច្ចុប្បន្នភាពស្ថានភាពរដ្ឋបាលលើតារាងបៀវត្សរ៍ប្រចាំខែ របស់មន្ត្រីរាជការនៃក្រសួងសុខាភិបាល។

ង- <u>ការងារសម្របសម្រួលការកែទម្រង់អន្តរវិស័យ</u>

- បានសម្របសម្រួល និង ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពរួមនៃការអនុវត្តការងារកំណែទម្រង់ទាំង៣ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៨
- បានចូលរួមប្រជុំពិភាក្សារវាងកំណែទម្រង់ទាំង៣ ដើម្បី (១)ត្រៀមរៀបចំសិក្ខាសាលាស្តីពីបុព្វហេតុសមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់របស់រាជរដ្ឋាភិបាល (២)ពិនិត្យលើវឌ្ឍនភាពផែនការសកម្មភាពរួម និងសកម្មភាពប្រទាក់ក្រឡាគ្នារវាងកំណែទម្រង់ទាំង៣ និង ការងារកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌
- បានចូលរួមកិច្ចប្រជុំ (១)ពិគ្រោះយោបល់កម្រិតនយោបាយ រវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលជប៉ុនស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (២)ត្រៀមកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០ នៅទីក្រុងប្រ៊ុចសែល និង (៣)ពិភាក្សាលើការកែទម្រង់ផែនការសកម្មភាពរួមដំណាក់កាលទី៣ (២០១៨-២០២០) និង សន្និសីទជាតិស្តីពីកំណែទម្រង់វិមជ្ឈការ

និង វិសហមជ្ឈការ លើប្រធានបទ (ក)មេរៀនបទពិសោធន៍ (ខ)បញ្ហាប្រឈម និង (គ)ចក្ខុវិស័យទៅអនាគត។

**២.១.១៣- ក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ**

- បានដាក់ឱ្យអនុវត្ត (១)អនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ និង (២)សេចក្តីណែនាំស្តីពី (ក)គោលការណ៍និងនីតិវិធីនៃការតែងតាំងនិងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបានបំពេញការងារនៅថ្នាក់ក្រោមជាតិ និង (ខ)គោលការណ៍និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ២៤០អនក្រ.បក សេចក្តីណែនាំលេខ ៧៨៨មស.សណន និងលេខ៧៨៩មស.សណន ជូនដល់មន្ត្រីរាជការចំនួន**១៩**រាជធានី ខេត្ត។
- បានសិក្សារៀបចំសេចក្តីព្រាងស្តីពីក្រមសីលធម៌និងក្រមប្រតិបត្តិសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**២.១.១៤- ក្រុមការងារយេនឌ័រ**

- បានចូលរួមកិច្ចប្រជុំ សន្និសីទ សិក្ខាសាលា និង វេទិកាសាធារណៈ តាមការអញ្ជើញរបស់ក្រសួងស្ថាប័នពាក់ព័ន្ធចំនួន១២ (នៅក្រៅប្រទេស**០១**លើក)
- បានចូលរួមជាប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (ក.ជ.ក.ស) ចុះបំពេញបេសកកម្មតាមដានវាយតម្លៃលើការអនុវត្តអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) អនុសាសន៍ សម្តេចតេជោនាយករដ្ឋមន្ត្រី និងច្បាប់ជាតិពាក់ព័ន្ធដែលទាក់ទងនឹងការលើកកម្ពស់ស្ថានភាព ជីវភាព ឋានៈ តួនាទី និងសុខុមាលភាពស្ត្រី នៅខេត្តព្រះវិហារ ខេត្តកែប និងខេត្តបន្ទាយមានជ័យ
- បានពិភាក្សាការងារជាមួយអង្គការ UN WOMAN ដើម្បីពិនិត្យសេចក្តីព្រាងកម្មវិធីជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ ឆ្នាំ២០១៨-២០២៣ ពីភាសាអង់គ្លេសមកភាសាខ្មែរ និងផែនការសកម្មភាពការងារបន្ត
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីលិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងអត្ថប្រយោជន៍មន្ត្រីរាជការ និងការលើកកម្ពស់ស្ត្រីក្នុងវិស័យមុខងារសាធារណៈ នៅខេត្តឧត្តរមានជ័យ

**២.១.១៥- ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- បានរៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសនីមួយៗ និងប្រចាំឆ្នាំ២០១៨ នៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី៣ (MAP3)
- បានរៀបចំផែនការសកម្មភាពដំណាក់កាលទី៣ (MAP3) ឆ្នាំ២០១៩ និង ផែនការថវិកាសម្រាប់ការអនុវត្តឆ្នាំ២០១៩
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីជំនាញហិរញ្ញវត្ថុ នៃអង្គភាពទាំង ២៩ បានចំនួន**០៣**លើក។

**២.១.១៦- សាលាភូមិន្ទរដ្ឋបាល**

- បានកសាងរូបស្តូបព្រះព្រហ្ម និង រៀបចំកសាងសួនច្បារថ្មី នៅក្នុងបរិវេណសាលាភូមិន្ទរដ្ឋបាល។
- បានធ្វើការបង្ហាញ Apps របស់ក្រសួងអប់រំ យុវជន និងកីឡា ជូនបេក្ខជនប្រឡងមធ្យមសិក្សាទុតិយភូមិ នៅស្រុកចិត្របុរី ខេត្តក្រចេះ។

ក- ការបណ្តុះបណ្តាលដំបូង

- បានធ្វើការបែងចែកប៉ុស្តិ៍បំពេញការងារជូនសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៩
- សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១០ បានចូលរៀនចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ ដែលត្រូវសិក្សារយៈពេលពីរឆ្នាំ និង ចែកចេញជាបីមុខជំនាញ គឺ (១)រដ្ឋបាលសាធារណៈ បានបញ្ចប់ចំនួន**១១/១៦**មុខវិជ្ជា (២)ទំនាក់ទំនងអន្តរជាតិ បានបញ្ចប់ចំនួន**១០/១៦**មុខវិជ្ជា និង (៣)សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបញ្ចប់ចំនួន០៧/១៤មុខវិជ្ជា
- សិស្សមន្ត្រីក្រមការជំនាន់ទី៧ "ជំនាន់កំណែទម្រង់ស៊ីជម្រៅ" បានការពាររបាយការណ៍ចុះកម្មសិក្សានៅក្រសួង ស្ថាប័ននិងសាលារាជធានី សាលាខេត្តចំនួន**១៩** និង សាលាខណ្ឌចំនួន**៩** ម្យ៉ាងទៀតសាលាបានរៀបចំសំណុំបែបបទបញ្ជូនសិស្សមន្ត្រីក្រមការជំនាន់កំណែទម្រង់ស៊ីជម្រៅទៅបំពេញការងារនៅតាមក្រសួង ស្ថាប័ន
- សាលាបានទទួលពាក្យស្នើសុំសិទ្ធិប្រឡងតាមប្រព័ន្ធ Online ពីបេក្ខជនចំនួន**៩៩៧នាក់** និង បានធ្វើការប្រឡងជ្រើសរើសនិងទទួលស្គាល់សិស្សមន្ត្រីក្រមការជំនាន់ទី៨ ចំនួន**១២៦នាក់** (ស្ត្រីចំនួន**៣៤នាក់** ស្មើនឹង**២៧%** និងជនពិការចំនួន**០២នាក់**)
- សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មីឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរចំនួន**៥វគ្គ** ដែលមានសិក្ខាកាមចំនួន**៧៨៨នាក់** (ស្ត្រីចំនួន**៣២២នាក់**) មកពី**២៣**ក្រសួង ស្ថាប័ន
- សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខណ្ឌថ្មីឆ្នាំ២០១៧ បានបណ្តុះបណ្តាលចំនួន**៤វគ្គ** ដែលមានសិក្ខាកាមចំនួន **៥៩៨នាក់** (ស្ត្រីចំនួន**២៣០នាក់**) និង ត្រៀមបើកវគ្គទី៥ នៅពាក់កណ្តាលខែមករា ឆ្នាំ២០១៩។

ខ- ការបណ្តុះបណ្តាលបន្ត

- កម្មសិក្សាការីទាំងអស់បានចូលរួមពិនិត្យសុខភាព ដែលរៀបចំដោយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត សហព័ន្ធស្ត្រី ដើម្បីសន្តិភាពពិភពលោក នៅសាលាភូមិន្ទរដ្ឋបាល
- កម្មសិក្សាការីឆ្នាំ២០១៨ បានចុះធ្វើការងារសង្គម ដើម្បីកសាង កែលម្អ ជួសជុល ទិញ ចែកសម្ភារៈ និងដាំកូនឈើ នៅខេត្តគោលដៅចំនួន៦ (ខេត្តកំពត ក្រចេះ កណ្តាល ឧត្តរមានជ័យ កំពង់ស្ពឺ និង តាកែវ) ដោយទទួលបានសមិទ្ធផលជាច្រើន រួមមាន បន្ទប់ទឹកចំនួន៤ ផ្លូវលំ១ខ្សែប្រវែង**១២០** ម៉ែត្រ ធ្វើដងទង់ជាតិចំនួន១ (ជួសជុល២) ធ្វើសួនច្បារចំនួន៣ កសាងក្លោងទ្វាសាលាចំនួន**២** កសាងប្រព័ន្ធបណ្តាញទឹកចំនួន៣ខ្សែ ទីលានបាល់ទាត់ចំនួន២ កសាងបណ្ណាល័យចំនួន**២** (កែលម្អ១) កសាងក្តាខៀនចំនួន**១** រូបសំណាកចំនួន**៣** ដាំកូនឈើជាង**៦០០**ដើម ធ្វើស្ពានបេតុងចំនួន**១** កសាងកន្លែងលាងដៃចំនួន**១** ធ្វើបង់អង្គុយចំនួន**៦** កសាង ប្រឡាយរំដោះទឹក**១ខ្សែ** ចែកសម្ភារៈសិក្សាដល់សិស្ស ចែកថ្នាំពេទ្យជូនប្រជាជន ធុងសម្រាមចំនួន**៥** ជីកស្រះទឹកចំនួន**១** ចែកមួកសុវត្ថិភាព ចំនួន**៣០០** ដាវដើលុបស្រះទឹក កសាងលូសម្រាប់ដុតសម្រាមចំនួន**៣** កែលម្អលាបរបងសាលារៀន។ល។
- បានចុះអនុស្សារណៈ រវាងក្រសួងមុខងារសាធារណៈ និង អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល វគ្គខ្លីជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានរៀបចំវគ្គវិក្រឹត្យការ ដែលមានរយៈពេល៩ខែ និង ការបណ្តុះណ្តាលវគ្គខ្លី ទទួលលទ្ធផលដូចខាងក្រោម៖

**ក- វគ្គវិក្រឹត្យការដែលមានរយៈពេល៩ខែ សរុបមានចំនួន ៤០២នាក់ (ស្ត្រី ៥៧នាក់)**

ខ- ការបណ្តុះបណ្តាលវគ្គខ្លីៗ សរុបមានចំនួន ១៤៩២នាក់ (ស្ត្រី ២២២នាក់)

គ- <u>ការងារស្រាវជ្រាវនិងទំនាក់ទំនងអន្តរជាតិ</u>

- ចូលរួមកម្មវិធីផ្សព្វផ្សាយតម្រង់ទិសដល់សិស្សានុសិស្សនៅតាមវិទ្យាល័យនានា នៅខេត្តកំពង់ចាម ព្រះសីហនុ បាត់ដំបង សៀមរាប និងក្នុងរាជធានីភ្នំពេញ។
- បានចុះអនុស្សារណៈ រវាងសាលាភូមិន្ទរដ្ឋបាល និងវិទ្យាស្ថានជាតិអភិវឌ្ឍន៍រដ្ឋបាលនៃព្រះរាជាណាចក្រថៃឡង់ដ៏
- បានជាវសៀវភៅអានជាភាសាខ្មែរនិងអង់គ្លេសចំនួន**៥២៥ក្បាល** ដាក់ក្នុងបណ្ណាល័យ។

## ២.២-<u>អង្គភាពថ្នាក់ក្រោមជាតិ</u>

### ២.២.១-<u>ការប្រើប្រាសក្របខណ្ឌ និង ឥណទានបៀវត្ស</u>

| ល.រ | រាជធានី-ខេត្ត | ចំនួនមន្ត្រី/បុគ្គលិក មន្ទីរ.ម.ស | | | ចំនួនមន្ត្រីទូទាំង រាជធានី-ខេត្ត | | ប្រពន្ធ | កូន | ឥណទានបៀវត្ស | ចំនួនមន្ត្រីជាប់ កិច្ចសន្យា | | ផ្សេងៗ[1] |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | កិច្ចសន្យា | សរុប | ស្រី | | | | សរុប | ស្រី | |
| ១ | ប.មានជ័យ | ២០ | ១១ | ៥ | ៨២០៦ | ៣៥២៧ | ២៦៦៣ | ៧៣៥៣ | ១៣៣៤២៥៣២៣៨៦០ | ៥៤៦ | ២១៤ | ៨២២៤ |
| ២ | បាត់ដំបង | ២៥ | ៨ | ៥ | ១២៥២៨ | ៦០៨៧ | ៣៣៥៤ | ១១៣៦០ | ១៩១០៩៥៣៣១៤៤០ | ៩០១ | ៣៦០ | ៧៩៨៩ |
| ៣ | កំពង់ចាម | ២២ | ៩ | ៥ | ១០៤៥៨ | ៥១០៧ | ៣១៤០ | ១០៩៩៣ | ១៣២៩៣៨៦៩៥៦០ | ៧៥៣ | ២៥៥ | |
| ៤ | កំពង់ឆ្នាំង | ២៣ | ៩ | ៥ | ៦៦៧៦ | ២៨១០ | ២១៣៣ | ៦៤៤៥ | ១០៧២២៣៨៨៨៥៧៨ | ៤០០ | ១៣៨ | ៦០៨៤ |
| ៥ | កំពង់ស្ពឺ | ១៧ | ១០ | ៥ | ៧៨៤៣ | ៣១០៧ | ៣០៤៥ | ៨១៨២ | ១២៨២៤១០២៤៦២០ | ៤៨១ | ១៧៦ | ១០៨២៧ |
| ៦ | កំពង់ធំ | ២៤ | ៥ | ៥ | ៧៦៤០ | ៣៤៥២ | ២២៧៧ | ៧៤៧៨ | ៨៦១០៥០៧៤៦៦៤ | ៥៩២ | ២២៥ | ២៩៥៨ |
| ៧ | កំពត | ២៣ | ៨ | ៥ | ៨៦៨៥ | ៣៥៧០ | ២៧៨៤ | ៨២៥៨ | ១៣៥០៥៥៥១៩៩៣០ | ៤៤៣ | ១៨៦ | ១០៣០៨ |
| ៨ | កណ្តាល | ២៨ | ១១ | ៥ | ១២៥១១ | ៥៨៩២ | ៣៨៧៨ | ១២៤២៩ | ១៩៩២២២៧៦៨០៨០ | | | ៤៥៦៨ |
| ៩ | កោះកុង | ២០ | ៥ | ៥ | ២៥៦៦ | ៨៧២ | ៧៥៦ | ១៧៤៦ | ៣៩៥២២៥៥៧២១៥ | ២៥៣ | ១២៨ | ១៥៩៥ |
| ១០ | ក្រចេះ | ២២ | ៧ | ៥ | ៤៨៥៤ | ២៤១៨ | ១១០៣ | ៤២៧៤ | ៦៥៧៨០៩៣៥២៣ | ៣៨៥ | ១៧៩ | ២៣៩៣ |
| ១១ | មណ្ឌលគិរី | ១២ | ៦ | ៥ | ២០២៦ | ៧៧០ | ៤២៦ | ១១៦០ | ៣០៥១៤៦៥៦៣៦៩ | ២៦៨ | ១៣៧ | |
| ១២ | រាជធានីភ្នំពេញ | ២៩ | ១០ | ៥ | ១៤៩៧៨ | ៧៤៨៨ | ៤០០០ | ១២៦៤២ | ២៣៧៨១៤២០៤៨១៤ | ៣៨៨៦ | ៨៥៥ | ៣១៦៥ |
| ១៣ | ព្រះវិហារ | ១៧ | ៩ | ៥ | ៣៩១២ | ១៥៤៨ | ៩៩៣ | ២៦៤៩ | ៦៤៤៧៧៥៣៥០០០ | ៣៤៨ | ១៣៥ | ៣៣៨១ |
| ១៤ | ព្រៃវែង | ១៩ | ៦ | ៥ | ១០៩១៥ | ៤៣១៤ | ៣៩៧២ | ១២៣៤៨ | ១៨៤០៧៨០១៧៨២២ | ៤២៨ | ១៤៥ | ១៤២៨៩ |
| ១៥ | ពោធិ៍សាត់ | ២០ | ១១ | ៥ | ៥៨៨៣ | ២៣៧៦ | ១៩៦៩ | ៥២៤១ | ៩៥៤៤៩២៨៤៩៦០ | ៤៨១ | ១៨០ | ៣៩៩៨ |
| ១៦ | រតនគិរី | ១១ | ១ | ៥ | ២៩៣៧ | ៩៦៤ | ៨៩៥ | ២០៧៧ | ៤១៣៩៦២៧៣២២៣ | ២៣២ | ១០៨ | ២៥៤២ |
| ១៧ | សៀមរាប | ២៥ | ៦ | ៥ | ១០៦៧១ | ៥៥០៧ | ២៣៣៨ | ៨៤៨១ | ១៥៨៣២៥៩៥៣២៧៨ | ៦៣៨ | | ២៩៧៣ |
| ១៨ | ព្រះសីហនុ | ២១ | ៨ | ៥ | ៣៥៤០ | ១៣០៤ | ១១១០ | ៣០១១ | ៥៤៤៣៥៥៣៨៤២០ | ២២៥ | ៨៦ | ១៨២៩ |
| ១៩ | ស្ទឹងត្រែង | ១៣ | ៥ | ៥ | ២៨៦៥ | ១២៥៣ | ៦៣៩ | ២០២៩ | ៤៤៧៦៦៦៦៩០២៨ | ៣២០ | ១៤០ | ២៦៣៤ |
| ២០ | ស្វាយរៀង | ២១ | ៧ | ៥ | ៦៧៩០ | ២៣៣៥ | ២៧៨៧ | ៦៧៥១ | ១០៣៦៩៧៣៤១៦១៥ | ៥១៨ | ១៧៩ | ៤៨១៤ |
| ២១ | ត្បូងឃ្មុំ | ១០ | ៥ | ៥ | ៧០៣០ | ៣១១៧ | ១៧៥៩ | ៥៨១៦ | ១១៦៥១៩៩០៥៩៦៩ | ៥០១ | | |
| ២២ | តាកែវ | ២៦ | ១២ | ៥ | ១១៦៣២ | ៤២៤២ | ៤៨៤៩ | ១៦០២៤ | ១៨៥៥៥០២៨៩១៤០ | ៤៧៣ | ១៣៣ | ១០៦៧៦ |
| ២៣ | កែប | ១៦ | ៥ | ៥ | ១៣៥០ | ៥៤៦ | ៣៤៥ | ១០៧០ | ២០០៨៩៧១២៣០០ | ២០៨ | ១០១ | ១១៣០ |
| ២៤ | ប៉ៃលិន | ១៨ | ៧ | ៥ | ១៧២១ | ៦៤៩ | ៤៩៤ | ១៣៤៨ | ២៦៤៥៤៤៨០០៣៨ | ២៧០ | ១៣១ | ១០២០ |
| ២៥ | ឧត្តរមានជ័យ | ១២ | ៣ | ៥ | ៣១៤៧ | ១១០៥ | ៩៥៣ | ២៥៣៩ | ៥៤៤១២៨៥៧១០៥ | ៤០៧ | ១៩៦ | ៣៨៨៥ |
| | **សរុប** | **៤៩៤** | **១៨៤** | **១២៥** | **១៧១៣៦៤** | **៧៤៣៦០** | **៥២៦៦២** | **១៦១៧០៤** | **២៤៥៧៧៤៦១៧០៥៥១** | **១៣០៥៦** | **៤៣៨៧** | **១១១២៨២** |

[1]ការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល

**៣-<u>សេចក្តីសន្និដ្ឋាន</u>**

ក្នុងរយៈពេលមួយឆ្នាំនេះ ក្រសួងមុខងារសាធារណៈ បានដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍន៍វិស័យមុខងារសាធារណៈ ព្រមទាំងការងារកែទម្រង់រដ្ឋបាលសាធារណៈ សម្រេចបាននូវសមិទ្ធផលគួរជាទីមោទនៈ រួមមានការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ការពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន ការកែលម្អការផ្តល់សេវាសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្ស ដើម្បីបង្កើនបៀវត្ស ប្រាក់ឧបត្ថម្ភ និងរបបសន្តិសុខសង្គម ព្រមទាំងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយដៃគូរអភិវឌ្ឍន៍នានា។

ផ្អែកលើទិសដៅការងារដែលបានកំណត់ ក្រសួងមុខងារសាធារណៈ នឹងប្រឹងប្រែងឱ្យអស់លទ្ធភាព ដើម្បីសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ក្នុងគោលបំណងកែលម្អវិស័យមុខងារសាធារណៈកម្ពុជាឱ្យឆ្លើយតបទៅនឹងការវិវត្តថ្មីៗនៃសង្គមជាតិ។ ក្នុងន័យនេះ រដ្ឋបាលសាធារណៈកម្ពុជានឹងត្រូវប្រែក្លាយឱ្យកាន់តែមានភាពរស់រវើក គុណភាព ភាពមានវិជ្ជាជីវៈ និងប្រសិទ្ធភាពក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដើម្បីបម្រើប្រជាពលរដ្ឋកាន់តែប្រសើរ៕

**សូមអរគុណ**!